ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# សាកលវិទ្យាល័យ អង្គរខេមរា
# ANGKOR KHEMARA UNIVERSITY

មហាវិទ្យាល័យ
College
សិល្បៈ មនុស្សសាស្ត្រ និងភាសា
Arts, Humanities and Languages

ឯកទេស៖ អក្សរសាស្ត្រខ្មែរ
Specialty: Khmer Literature

# មុខវិជ្ជា៖ សង្គមភាសាវិទ្យា

## ប្រធានបទ

***"ការប្រើប្រាស់ពាក្យតាមតំបន់ខេត្តតាកែវ, ខេត្តសៀមរាប"***


បង្រៀននិងណែនាំដោយ៖ **លោកគ្រូ សុស សុផល**

រៀបរៀងដោយនិស្សិតថ្នាក់ ៖ បរិញ្ញាបត្រ

Witten by Undergraduate Students

១ វិបុល មករា (ស្រី) ២ ហ៊ីន សុភ័ណ្ឌា (ស្រី)

៣ ផន សុគន់ (ស្រី) ៤ ឌី ជីវ័ន្ត (ប្រុស)

និស្សិតអក្សរសាស្ត្រខ្មែរ ជំនាន់ទី១៣-១៤ វគ្គទី០១ ឆមាសទី០២ ឆ្នាំទី០៤ សាខាពោធិ៍សាត់


ព.ស២៥៦៩ ឆ្នាំសិក្សា៖២០២៤-២០២៥ គ.ស ២០២៤

# អារម្ភកថា

គ្រប់ប្រទេស ជាតិសាសន៍ទាំងអស់ក្នុងពិភពលោកយើងនេះ ដើម្បីអាចប្រាស្រ័យទាក់ទងគ្នាបានមនុស្សតែងតែពឹងផ្អែកលើភាសាជាចម្បងហើយភាសាទាំងនោះតែងតែមានភាពខុសប្លែក ចំណុចពិសេសផ្សេងៗគ្នាទៅតាមប្រទេសជាតិនីមួយៗ។ ដោយឡែកបើយើងក្រឡេក មកមើលប្រទេសកម្ពុជាយើងដែលជាប្រទេសមួយដែលសម្បូរទៅដោយ ប្រវត្តិសាស្ត្រ វប្បធម៌ និងសិល្បៈ ទំនៀមទម្លាប់ សាសនា ព្រមទាំងអរិយធម៌ជាច្រើនដូចទៅនឹងប្រទេសនានា។ លើសពីនោះប្រទេសកម្ពុជាយើងបើនិយាយអំពីការប្រើប្រាស់ភាសាក្នុងជីវភាពប្រចាំថ្ងៃវិញនោះតែងតែមានចំណុចពិសេសដោយពីតំបន់មួយទៅតំបន់មួយនិយមប្រើភាសាតាមតំបន់រៀងៗខ្លួនឬនិយាយម្យ៉ាងទៀតថាគ្រាមភាសាប្រចាំតំបន់។ ទន្ទឹមនឹងនេះដូចដែលបានរៀបរាប់ខាងនោះ ទើបខ្ញុំបាទ-នាងខ្ញុំបានលើកយកពីការការប្រើប្រាស់ភាសាតាមតំបន់របស់ ប្រជាជនយើងយកមកចងក្រងធ្វើ ជាឯកសារ ទុកជាប្រយោជន៍ទៅថ្ងៃមុខ។ យ៉ាងណាមិញ ស្នាដៃដ៏តូចមួយនេះគឺគ្រាន់តែជួយបំពេញចំណេះដឹងបន្ថែមដើម្បីឱ្យបានដឹងបានស្គាល់នឹងទទួលចំណេះដឹង ភាសាតាមតំបន់ខ្លះៗ ប៉ុណ្ណោះវាមិនមែនជាឯកសារជាគោលឡើយ។ មួយវិញទៀតជាការលើកស្ទួយនិងរក្សាភាសាតាមតំបន់របស់អ្នកស្រុកភូមិរបស់យើងដែលបង្កើតដោយដូនតាខ្មែរយើងតាំងពីបុរាណកាលថែមទៀងផង។

ជាចុងបញ្ចប់ខ្ញុំបាទ-នាងខ្ញុំសូមខន្តីអភ័យទោសរាល់កំហុសខុសឆ្គងដោយអចេតនាក្នុងការសរសេរកិច្ចការស្រាវជ្រាវមួយនេះ។ ទៀតសោតបទពិសោធន៍និងចំណេះដឹងក្នុងការស្រាវជ្រាវឯកសាររបស់ខ្ញុំនៅមានកម្រិតនៅឡើយហេតុនេះហើយកិច្ចការស្រាវជ្រាវមួយនេះគឺចៀសមិនផុតពីកំហុសខុសឆ្គងនិងភាពខ្វះខាតឡើយ។ ដូច្នេះហើយក្រុមរបស់ខ្ញុំ សូមស្វាគមន៍យ៉ាង រីករាយ ពីសំណាក់មតិ យោបល់និងមតិកែលម្អ ផ្សេងៗពីនិស្សិត ពិសេសលោកគ្រូ**សុស សុផល** ដែលអាចជួយកែលម្អកិច្ចការស្រាវជ្រាវមួយនេះឲ្យកាន់តែមានភាពល្អប្រសើរឡើងថែមមួយកម្រិតទៀត។

*ពោធិ៍សាត់ ថ្ងៃពុធ ទី១៤ ខែឧសភា ឆ្នាំ២០២៥*

# សេចក្តីថ្លែងអំណរគុណ

ទន្ទឹមនឹងការកកើតនូវស្នាដៃឡើងបានជាលទ្ធផលនេះខ្ញុំបាទសូមសម្តែងនូវអំណរគុណជាអនេកប្រការចំពោះ ៖

លោកឪពុក អ្នកម្តាយនៃខ្ញុំទាំងឡាយជាបុព្វាចារ្យនឹងជាព្រះអរហន្តដ៏ប្រសើររបស់ខ្ញុំបាទដែលលោកបានផ្តល់នៅកំណើត ហើយចិញ្ចឹមបីបាច់ថែរក្សាដោយព្រហ្មវិហារ ធម៌។ ជានិច្ចកាលលោកតែងតែណែនាំចង់ឲ្យក្លាយជាគ្រាប់ពូជដ៏មានតម្លៃ មួយ។

លោកគ្រូ អ្នកគ្រូទាំងអស់តាំងពីថ្នាក់បឋមសិក្សារហូតមកដែលលោកបានបង្ហាត់បង្រៀនឲ្យខ្ញុំបាទនូវ ទ្រព្យសម្បត្តិដែលមិនអាចកាត់ថ្លៃបានពោលគឺចំណេះវិជ្ជា ព្រមទាំងសីលធម៌ សុជីវធម៌ ក្នុងសង្គមធ្វើឲ្យក្លាយ ជាធនធានដ៏មានតម្លៃមួយសម្រាប់សង្គមជាតិ។

បណ្ឌិត **នូ ចាន់សុភី** សាកលវិទ្យាធិការ នៃសាកលវិទ្យាល័យអង្គរខេមរា និងគណៈគ្រប់គ្រងនៃ សាកលវិទ្យាល័យអង្គរខេមរាទាំងអស់ធ្វើឲ្យខ្ញុំបានទទួល បានចំណេះដឹងដ៏មានតម្លៃ សម្រាប់ជួយខ្លួនឯង គ្រួសារ និងសង្គមជាតិបានមួយចំណែក។

សាស្ត្រាចារ្យក្នុងឯកទេស អក្សរសាស្ត្រខ្មែរនៃសាកលវិទ្យាល័យអង្គរខេមរាទាំងអស់ដែលបានខិតខំ ប្រិតប្រៀនតម្រែតម្រង់នៅមុខវិជ្ជាទាំងឡាយក្នុងជំនាញអក្សរសាស្ត្រខ្មែរញ៉ាំងឲ្យខ្ញុំបាទទទួលនូវចំណេះ ដឹងយ៉ាងស្រួចស្រាល់លើជំនាញរបស់ខ្ញុំ។ ជាពិសេសសូមអរគុណជាអនេក ចំពោះលោកគ្រូ **សុស សុផល** ដែលបង្រៀនលើមុខវិជ្ជា*សង្គមភាសាវិទ្យា*ដែលបានណែនាំកែតម្រូវលើកិច្ចការស្រាវជ្រាវមួយនេ។

❁❁❁

# ឧទ្ទិសកថា

ខ្ញុំសូមឧទ្ទិសស្នាដៃនេះជូនចំពោះ៖

- វិញ្ញាណក្ខន្ធបុព្វបុរសខ្មែរគ្រប់រូបដែលបានធ្វើពលិកម្មគ្រប់បែបយ៉ាងដើម្បីការពារជាតិមាតុភូមិ។
- វិញ្ញាណក្ខន្ធកវី បណ្ឌិត អ្នកនិពន្ធ អ្នកប្រាជ្ញខ្មែរគ្រប់ជំនាន់ៗ ដែលបានខិតខំថែរក្សាអក្សរសាស្ត្រជាតិឱ្យរីកចម្រើនគង់វង្សរហូតមកដល់សព្វថ្ងៃ។
- វិញ្ញាណក្ខន្ធសម្ដេចព្រះសង្ឃរាជ ជួន ណាត ដែលព្រះអង្គបានបន្សល់ស្នាដៃដ៏វិសេសវិសាល សម្រាប់កូនខ្មែរគ្រប់ជំនាន់នោះគឺ សៀវភៅវចនានុក្រមខ្មែរ។
- វិញ្ញាណក្ខន្ធនៃបុព្វការីជនរបស់ខ្ញុំទាំងអស់។

សូមជួយទ្រទ្រង់វិស័យអក្សរសាស្ត្រជាតិឱ្យកាន់តែរីកចម្រើនជានិច្ចនិរន្តរ៍។

# មាតិកា


-ជំពូកទី១៖ សេចក្ដីផ្ដើម........................................................................... ទំព័រ១

-ជំពូកទី២៖ សារៈសំខាន់ចំពោះកិច្ចការស្រាវជ្រាវ ................................................... ទំព័រ១

-ជំពូកទី៣៖  គោលបំណង........................................................................ ទំព័រ២

-ជំពូកទី៤៖ បង្ហាញពីប្រវត្តិខេត្តទាំង២ ................................................................ ទំព័រ២

-ជំពូកទី៥៖ ការប្រើប្រាស់ពាក្យតាមតំបន់ ............................................................ ទំព័រ៤

-សេចក្ដីសន្និដ្ឋាន ................................................................................... ទំព័រ១០

# ជំពូកទី១

## សេចក្តីផ្តើម

ក្រុមរបស់យើងខ្ញុំបានធ្វើកិច្ចការស្រាវជ្រាវមួយដែលស្រាវជ្រាវអំពីការប្រើប្រាស់ពាក្យទូទៅជាមួយការប្រើប្រាស់ពាក្យក្នុង ខេត្តតាកែវ និងខេត្តសៀមរាប។ ពាក្យតាមតំបន់មានន័យថាជាពាក្យដែលកើតមាននៅក្នុងតំបន់នោះតាំងពីបុរមបុរាណមក ហើយអ្នកស្រុកគេនិយមប្រើប្រាស់ក្នុងជីវភាព រស់នៅប្រចាំថ្ងៃ សម្រាប់ទំនាក់ទំនងគ្នានិងសម្គាល់វត្ថុផ្សេងៗជាដើម។

# ជំពូកទី២

## សារៈសំខាន់ចំពោះកិច្ចការស្រាវជ្រាវ

សារៈសំខាន់ចំពោះកិច្ចការស្រាវជ្រាវស្តីពីការប្រើប្រាស់ពាក្យរបស់ខេត្តតាកែវ, ខេត្តសៀមរាបនេះ ពិតជាមានសារៈសំខាន់ណាស់ដែលធ្វើឱ្យយើងដឹងពីកំណកំណើតនៃភាសាឬពាក្យតាមតំបន់នីមួយៗខេត្តតាកែវនិងខេត្តសៀមរាប។ ការស្រាវជ្រាវនេះនឹងជួយធ្វើឲ្យប្រជាជនខ្មែរ ក៏ដូចអ្នកសិក្សាបានយល់ដឹងពីឫសគល់ដើមហេតុដែលនាំឲ្យមានការបង្កើតពាក្យក្នុងតំបន់នេះ។

# ជំពូកទី៣

## គោលបំណង

ការខិតខំរបស់ក្រុមយើងខ្ញុំអំពីធ្វើការស្រាវជ្រាវនេះឡើងគឺក្នុងគោលបំណងដឹងពីការកើតពាក្យដែលនិយមប្រើរបស់ប្រជាជនរស់នៅក្នុងនោះហើយយកពាក្យទាំងនោះមកចងក្រងរក្សាទុកនិងដើម្បីជួយផ្សព្វផ្សាយដល់ក្មេងជំនាន់ក្រោយបានយល់ដឹង។ ហើយជាទុនមួយសម្រាប់ជាជំនួយដល់អ្នកដែលសិក្សាស្រាវជ្រាវជំនាន់ក្រោយ។

# ជំពូកទី៤

## បង្ហាញពីប្រវត្តិ

### ១. ខេត្តតាកែវ

ខេត្តតាកែវ គឺជាខេត្តមួយដែលស្ថិតនៅភាគខាងត្បូងនៃប្រទេសកម្ពុជា។ ស្ថិតនៅខាងលិចទន្លេបាសាក់ ខេត្តតាកែវ មានព្រំប្រទល់ជាប់នឹងខេត្តកំពត ខាងលិចជាប់ខេត្តកំពង់ស្ពឺខាងជើងឆៀងខាងលិច និងខេត្តកណ្ដាលនៅខាងជើងនិងខាងកើត។ ហើយព្រំប្រទល់ភាគខាងត្បូងរបស់ខេត្តគឺព្រំដែនអន្តរជាតិជាមួយវៀតណាម(ខេត្តមាត់ជ្រូក)។ តាមជំរឿនប្រជាជននៅថ្ងៃទី៣ ខែមីនា ឆ្នាំ១៩៩៨ ខេត្តតាកែវមានចំនួន ៧៩០,១៦៨នាក់ និងជំរឿនថ្ងៃទី៣ ខែមីនា ឆ្នាំ២០១៨ ប្រជាជនមានចំនួន ៨៤៤,៩០៦នាក់។ តាមការធ្វើជំរឿនប្រជាជនកម្ពុជានៅថ្ងៃទី៣ ខែមីនា ឆ្នាំ២០១៩ បានបង្ហាញថា ខេត្តតាកែវមានប្រជាជនសរុបចំនួន ៨៩៩,៤៨៥នាក់និងមានដង់ស៊ីតេចំនួន ២៥២.៥នាក់ក្នុងមួយគីឡូម៉ែត្រការ៉េ។

## ២. ខេត្តសៀមរាប

ខេត្តសៀមរាបជាអតីតខេត្តខ្មែរមួយឈ្មោះថាខេត្តមហានគរ។ការប្តូរឈ្មោះជាខេត្តសៀមរាបនេះក្នុងរជ្ជកាលព្រះបាទច័ន្ទរាជា។ នៅក្នុងឆ្នាំ ១៥៣០ គ.ស(តាមពង្សាវតា)មូលហេតុបានជាផ្លាស់ប្តូរឈ្មោះខេត្តនេះបានបញ្ជាក់ថានៅក្នុងឆ្នាំ ១៥៣០ គ.ស ស្តេចអយុធ្យាបានបញ្ជាឲ្យកងទ័ពខ្លួនវាយលុកកម្ពុជានៅខេត្តមហានគរដើម្បីបង្ក្រាបការមិនចុះញ៉មរបស់ព្រះបាទច័ន្ទរាជា។ទ័ពសៀមដណ្តើមខេត្តមហានគរមួយរយៈហើយមេដឹកនាំបានទៅទស្សនាប្រាសាទគួរឲ្យយ៉ាងស្ញប់ស្ញែង។បន្ទាប់មកទ័ពស្តេចសៀមនេះបានជួបនឹងទ័ពស្តេចខ្មែរនៅតំបន់អង្គរហើយបានប្រយុទ្ធគ្នាធ្វើឲ្យកងទ័ពសៀមទទួលបរាជ័យយ៉ាងធ្ងន់ធ្ងរ។ក្រោយពីទទួលបានជ័យជំនះមកព្រះបាទច័ន្ទរាជាបានបរិញ្ញត្តិឲ្យប្តូរឈ្មោះខេត្តមហានគរនេះទៅជាខេត្តសៀមរាបវិញដែលមានន័យថា *"ទ័ពសៀមត្រូវបង្ក្រាបឲ្យរាប"*នៅទីនេះ។

# ជំពូកទី៥

## ពាក្យទូទៅជាមួយពាក្យប្រើប្រាស់ក្នុងខេត្តតាកែវ

| ពាក្យនិយាយទូទៅ | ពាក្យនិយាយក្នុងខេត្តតាកែវ |
|---|---|
| ១. ការ៉ុង | ១.ស្បោង,កន្ទេរ |
| ២.ផ្លូវកោង | ២.ផ្លូវកេល |
| ៣.ឆេងម៉េង | ៣.ធឹងមឹង |
| ៤.ក្បាក់ | ៤.ចានដែក,ម៉ាង |
| ៥.ឡាំង | ៥.ប៉ោត |
| ៦.ទឹកភ្លៀង | ៦.ទឹកទន្លេ |
| ៧.ត្រសក់ | ៧.អាសក់ |
| ៨.ត្រឡាច | ៨.អាឡាច |
| ៩.ល្ពៅ | ៩.អាពៅ |
| ១០.សម្លូ | ១០.ម្លូ |
| ១១.ពូ | ១១.គូ |
| ១២.ប៉ា | ១២.ទា |
| ១៣.យាយតា | ១៣.យាយកុង |
| ១៤.ផ្សារជ្រៃ | ១៤.ផ្សារឈៃ |
| ១៥.ផ្សារព្រៃស្អំ | ១៥.ផ្សារកែកំ |

| | |
|---|---|
| ១៦.ព្រៃល្វា | ១៦.កែវា |
| ១៧.ល្ហុង | ១៧.អាហុង |
| ១៨.កណ្តុរ | ១៨.កាលុល |
| ១៩.ចង្កោម | ១៩.កោម |
| ២០.ខ្ទុល | ២០.កាតុលម៉ុល |
| ២១.ដើមប្រលិត | ២១.ដើមរំចង់ |
| ២២. គោយន្ត | ២២.កាលេថង |
| ២៣. ម៉ូតូឌុប | ២៣. ម៉ូតូអូម |
| ២៤. ឆ្ងាញ់ណាស់ | ២៤. ឆ្ងាញ់មាំហ៉ា |
| ២៥. មិនអីទេ | ២៥. មិនអ៊ុយតេ |
| ២៦. រត់ | ២៦. មិត |
| ២៧.ប្រញាប់ | ២៧. កុន |
| ២៨. ស្រែស្រូវ | ២៨. សែសូវ |
| ២៩. ឱ្យកូនញ៉ាំបាយខ្លួនឯង | ២៩. ឱ្យកូនញ៉ាំបាយដៃឯង |
| ៣០. កូនបៀមបាយ | ៣០. កូនជញ្ជក់បាយ |
| ៣១. កូនយំទាររបៅ | ៣១. កូនហៅរអឹម |
| ៣២. កូនដេកទ្រមក់ | ៣២. កូនដេកធំ |
| ៣៣. ចរឹក | ៣៣. កំប្រុក |

| | |
|---|---|
| ៣៤. កំរិស | ៣៤. ខ្មេះ |
| ៣៥. ប្រធាក | ៣៥. វាត់ឈៀង |
| ៣៦. ទៅត្បូង | ៣៦. ទៅបូង |
| ៣៧. ត្រី | ៣៧. ផៃ |
| ៣៨. ពេតប៉ោង | ៣៨. ផ្លោក |
| ៣៩. ស្ករត្នោត | ៣៩. ស្ករពាង |
| ៤០. ព្រះច័ន្ទ | ៤០. ខែអូង |
| ៤១.ស្អាត | ៤១.ឆ្អាត |
| ៤២.ទៅ | ៤២.តូវ |
| ៤៣.ជ្រុះ | ៤៣.រុះ |
| ៤៤.កង្ការ | ៤៤.ចង្ហាល |
| ៤៥.ថង់,ស្បោង | ៤៥.កាថង់ |
| ៤៦.កំពង់ស្ពឺ | ៤៦.ពង់ពឺ |
| ៤៧.ក្លិនឈ្ងៀម | ៤៧.ឈ្ងិត |
| ៤៨.កាពិ | ៤៨.គី |
| ៤៩.ប្រហុក | ៤៩.ប៉ាហួក |
| ៥០.ស្ទឹង | ៥០.ច្ទឹង,ឆ្ទឹង |
| ៥១.ប្រាំរយ | ៥១.ផែមហោយ |

| | |
|---|---|
| ៥២.ផ្ទះ | ៥២.ទះ |
| ៥៣.ទឹកត្រី | ៥៣.ទឹកថី |
| ៥៤.ខ្ញុំ | ៥៤.ញ៉ុម |
| ៥៥.ក្រុង | ៥៥.ខ្រុង |
| ៥៦.ឪឡឹក | ៥៦.អាឡឹក |
| ៥៧.ច្រើន | ៥៧.ម៉ាកាក្លុស |
| ៥៨.តាឡូនតន | ៥៨.ឡូនតន |
| ៥៩.គ្រូ | ៥៩.឵យូ |
| ៦០.ស្លាប់ | ៦០.លាប់ |
| ៦១.បឹង | ៦១.ធឹង |
| ៦២.ស្ដាប់ | ៦២.ណាប់ |
| ៦៣.ចានដែក,កាធុន | ៦៣.ខ្លាំម |
| ៦៤.ផ្ដិល | ៦៤.បោយទឹក |
| ៦៥.ស្រុកខ្ញុំ | ៦៥.ធុកញុម |
| ៦៦.ស្រឡាញ់ | ៦៦.លាញ់ |
| ៦៧.សារាយ | ៦៧.ចាហ្វួយ |
| ៦៨.មើលងាយ | ៦៨.មើលងារ |
| ៦៨.កំសៀវ | ៦៨.កាសៀវ |

| ពាក្យនិយាយទូទៅ | ពាក្យនិយាយក្នុងខេត្តសៀមរាប |
|---|---|
| ១. ភក់ល្បាប់ | ១. ភក់ |
| ២. បង់អង្គុយ | ២.តុអង្គុយ |
| ៣. ច្រើន | ៣. ការប៉េស |
| ៤. ផុងជើង | ៤. ឡុះជើង |
| ៥. ត្រប់ផ្លោកគោ | ៥. ត្រប់ក្តគោ |
| ៦. របស់ស្អុយ | ៦. ការលូង |
| ៧. ច្រើនណាស់ | ៧. ច្រើនឡើស |
| ៨. ឧស្សាហ៍ | ៨. ចាណាប់ |
| ៩. ហត់ | ៩. សោ |
| ១០. ជិតអស់ | ១០.ស្បើយ |
| ១១. ធុង | ១១. ឡាំង, កាថាំង |
| ១២. ក្បាក់ | ១២. ការធន់ |
| ១៣. កែងខោអាវ | ១៣. កាងខោអាវ |
| ១៤. ពោះវៀនម៉ូតូ | ១៤. សង្អែល |
| ១៥. សំបកម៉ូតូ | ១៥. អង់ការឡុប |
| ១៦. ល្បែងមុខស្នាក់ | ១៦. ល្បែងគុង |
| ១៧. ធីបអូសត្រី | ១៧. មងអូសត្រី |

| | |
|---|---|
| ១៨. សន្ទូចរនង | ១៨. សន្ទូចសាង |
| ១៩. ផ្លែសាខរ | ១៩. ផ្លែសាខើ |
| ២០.ចានគោម | ២០. ចានការឡប |
| ២១. កញ្ច្រែង | ២១. កាត្រា |
| ២២. អាចម៌ដែក | ២២. ប្រាស់ដុះធ្នាំង |
| ២៣. ចបជីក | ២៣. ចានីជ |
| ២៤. កាំបិតក្រចៃត | ១៤. តាំងតោ |
| ២៥. ចង្អើរអាំងត្រី | ២៦. ចាអើអាំងត្រី |
| ២៦. ស្ងួរដដែលៗ | ២៦. ស្ងួរដែលៗ |
| ២៧. ពិបាក | ២៧. យ៉ាក |
| ២៨. ខ្មាស់អៀន | ២៨. អៀល |
| ២៩. សម | ២៩. សន្ទំ |
| ៣០. ធ្វើអី | ៣០.ធ្វើស្តុយ |
| ៣១. អាក្រក់ | ៣១.ប្រោ |
| ៣២. ស្វាត់ច្រៀប | ៣២. ស្វាត់អន្ត្រីង |

# សេចក្តីសន្និដ្ឋាន

ឆ្លងតាមរយៈការសិក្សាពីការប្រើប្រាស់អំពីពាក្យទូទៅជាមួយនឹងខេត្តតាកែវនិងការប្រើប្រាស់អំពីពាក្យទូទៅជាមួយនឹងខេត្តសៀមរាមរួចមក ឃើញថាពាក្យតាមតំបន់នីមួយៗ គឺមានការប្រើប្រាស់ពាក្យប្រចាំថ្ងៃមួយចំនួនដូចគ្នា ហើយពាក្យមួយចំនួនទៀតក៏មានការប្រើខុសគ្នាផងដែរ។

ការពិនិត្យពាក្យតាមតំបន់ក្នុងខេត្តទាំង២នេះអាចឲ្យយើងឃើញថាពាក្យក្នុងតំបន់នីមួយៗមានការប្រើប្រាស់ពាក្យនិយាយមានភាពប្រហាក់ប្រហែលគ្នា ប៉ុន្តែមានការលំអៀងសូរវាងគ្នាបន្តិចបន្តួចប៉ុណ្ណោះ ។ ជារួមការសិក្សាពាក្យតាមតំបន់គឺជាការបង្ហាញពីភាពខុសគ្នានៃវប្បធម៌និងទីតាំងភូមិសាស្ត្ររបស់តំបន់នីមួយៗ។ ការយល់ដឹងពីពាក្យនេះមិនត្រឹមតែជួយឲ្យយើងយល់ពីអត្តសញ្ញាណតំបន់នីមួយៗទេ ប៉ុន្តែបង្កើនការយល់ចំពោះការប្រើប្រាស់ពាក្យក្នុងភាសាខ្មែរតាមតំបន់និងការរក្សាទុកវប្បធម៌ជាតិនិងមូលដ្ឋានផងដែរ។

- ឯកសារយោង

– ដកស្រង់ចេញពី https://km.wikipedia.org/wiki/

– *ដកស្រង់ចេញពី* https://km.wikipedia.org/wiki/

– ការសម្ភាសផ្ទាល់ជាមួយ *"លោកខេង ទ្រឿន ជាគរុនិស្សិតដែលមានស្រុកកំណើតក្នុងខេត្តសៀមរាប"។*

– ការសម្ភាសផ្ទាល់ជាមួយ *"លោកជា ជីមដែលមានស្រុកកំណើតនៅខេត្តតាកែវ"។*